**សុន្ទរកថា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ថ្លែងក្នុង**

**ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ កញ្ចប់ថវិកាចំនួន**

**១០០ លានដុល្លារអាមេរិក សម្រាប់គាំទ្រការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ**

**ក្រោយវិបត្តិជំងឺកូវីដ-១៩"**

**រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០២២**

៙៙៙✵៚៚៚

*- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

*- សមាជិក, សមាជិកាទាំងអស់ នៃអង្គពិធីជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានចូលរួមជាអធិបតី ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **កញ្ចប់ថវិកាចំនួន ១០០ លានដុល្លារអាមេរិក សម្រាប់គាំទ្រការស្តារកំណើនសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩** ។ ខ្ញុំសូមជម្រាបជូនថា កញ្ចប់ថវិកានេះជាផ្នែកមួយនៃការជំរុញការអនុវត្ត **ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣** ដែលរាជរដ្ឋាភិបាលកម្ពុជាទើបបានអនុម័ត និង ប្រកាសដាក់ឱ្យអនុវត្តនាពេលថ្មីៗនេះ ។

ខ្ញុំសូមយកឱកាសនេះគូសរំលេចជូនថា ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ ដូចបណ្តាប្រទេសនានាក្នុងតំបន់ និង ពិភពលោកផងដែរ, ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និង សុខភាពសាធារណៈមានភាពយឺតយ៉ាវ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២០ កន្លងទៅនេះ, សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានក្នុងអត្រា -៣,១% បណ្តាលមកពីការធ្លាក់ចុះយ៉ាងគំហុកនៃវិស័យសំខាន់ៗ ដូចជា

ទេសចរណ៍, សំណង់ និង អចលនទ្រព្យ ខណៈដែលវិស័យកសិកម្មនៅរក្សាបាននូវកំណើនវិជ្ជមាន ។ ទន្ទឹមនេះ, សហគ្រាសឯកជន ជាពិសេស សហគ្រាសធុនតូច និង មធ្យម ក្នុងវិស័យសេវាកម្ម ក៏ទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងផងដែរ ។

យ៉ាងណាមិញ, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២១ ត្រូវបានប៉ាន់ស្មានថា ងើបឡើងវិញបន្តិច ពោលអាចសម្រេចបានកំណើនក្នុងរង្វង់ ៣,០% ដោយសារការបើកដំណើរការសកម្មភាពសេដ្ឋកិច្ច-សង្គម ទាំងស្រុងឡើងវិញ ចាប់ពីត្រីមាសទី ៤ នៃឆ្នាំ ២០២១, ភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋ-កិច្ចសកល ព្រមទាំងការផ្តល់កិច្ចអន្តរាគមនានារបស់រាជរដ្ឋាភិបាល។ ជាការពិតណាស់, សមិទ្ធិកម្ម សេដ្ឋកិច្ចនេះ គឺជាលទ្ធផលនៃការអនុវត្តវិធានការប្រកបដោយបុរេសកម្ម និង ប្រសិទ្ធភាពខ្ពស់របស់ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំ និង ការគិតគូរគ្រប់ជ្រុងជ្រោយ ប្រកបដោយភាពឈ្លាសវៃ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជា-ណាចក្រកម្ពុជា** ក្នុងការដាក់ចេញ នូវវិធានការសុខាភិបាល និង រដ្ឋបាលនានា រួមជាមួយនឹងការ កំណត់យកការចាក់វ៉ាក់សាំងកូវីដ-១៩ ជាយុទ្ធសាស្ត្រដ៏គន្លឹះ ដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហ-គមន៍ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ស្តារ និង ជំរុញការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុង ស្រុក ។ បន្ថែមលើនេះ, ដើម្បីសម្រាលបន្ទុករបស់អាជីវកម្ម ក៏ដូចជារក្សាលំនឹងជីវភាពរបស់ប្រជា-ពលរដ្ឋ, រាជរដ្ឋាភិបាលបានផ្តល់ការអនុគ្រោះផ្នែកសារពើពន្ធ ដល់សហគ្រាសឯកជន នៅក្នុងវិស័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារវិបត្តិជំងឺកូវីដ-១៩, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ទៅដល់កម្មករ-និយោជិត ដែលបានបាត់បង់ការងារ និង ប្រជាជនក្រីក្រ និងកម្មវិធីផ្សេងៗទៀតជាច្រើន ។

ទោះជាយ៉ាងនេះក្តី, ថ្មីៗនេះ, ការងើបឡើងវិញនៃការរីករាលរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុង ប្រទេស ដែលឆ្លុះបញ្ចាំងតាមការកើនឡើងខ្ពស់នៃករណីឆ្លងនៃវីរុសបំប្លែងខ្លួនថ្មីកូវីដ-១៩ អូមីក្រុង បានបង្កជាបញ្ហាប្រឈមមួយ ដែលអាចនឹងបន្ទច់បង្អាក់ការងើបឡើងវិញ នូវសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ច និង បង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ។ ក្នុងន័យនេះ, ខ្ញុំសូមលើកទឹកចិត្តដល់ ភាគីពាក់ព័ន្ធទាំងអស់, ទាំងផ្នែករដ្ឋ និង ឯកជន, បន្តចូលរួមអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល រួមមាន វិធានការសុខាភិបាល, វិធានការរដ្ឋបាល និង វិធានការអប់រំ ដើម្បីចូលរួមទប់ស្កាត់ និង កាត់បន្ថយ ការឆ្លង ព្រមទាំងការពារសុខុមាលភាព និង អាយុជីវិតរបស់ប្រជាជន ពិសេស ដើម្បីបញ្ចៀសផល ប៉ះពាល់អវិជ្ជមានដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

**"ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣"** មានគោលបំណងស្តារកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និង រយៈពេលមធ្យម ឱ្យត្រឡប់ទៅកំណើនសក្តានុពល និង ពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និង បរិយាប័ន្ន ក្នុងរយៈ-ពេលវែង ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តាកំណើនសេដ្ឋកិច្ចនេះបានដាក់ចេញ នូវសកម្មភាពអនុវត្តជាក់ស្តែងនៅក្នុងវិស័យជាច្រើន ។ សម្រាប់ថ្ងៃនេះ, ថវិកា ១០០ លានដុល្លារ នឹងត្រូវប្រើប្រាស់ ដើម្បីជួយលើកស្ទួយវិស័យកសិកម្ម និង វិស័យសហគ្រាសធុនតូច និង មធ្យម ដែលជាវិស័យពីរដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ, ទាំងក្នុងការបង្កើតការងារ, កែ-លម្អជីវភាពរស់នៅរបស់ប្រជាជន និង កំណើនសេដ្ឋកិច្ចជាតិ ។

រដ្ឋាភិបាលកម្ពុជា ចាត់ទុកការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ពិសេសសហគ្រាសដែលស្ថិតក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជា កសិកម្ម, កសិ-ឧស្សាហកម្ម, ការកែច្នៃម្ហូបអាហារ, កម្មន្តសាល, គ្រឿងបង្គុំ និង ទេសចរណ៍ ជាដើម ជាអាទិភាពគោលនយោបាយមួយដ៏សំខាន់ ។ ជាការពិត, សហគ្រាសធុនតូច និង មធ្យម មិនត្រឹមតែចូលរួមដល់ការគាំទ្រកំណើនសេដ្ឋ-កិច្ចកម្ពុជា និង ការបង្កើតការងារប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើនភាពធន់របស់សេដ្ឋកិច្ចជាតិទៅនឹងវិបត្តិផងដែរ ។ ជាក់ស្តែង, សហគ្រាសធុនតូច និង មធ្យមមានប្រមាណ ៩៨% នៃអាជីវកម្មទាំងអស់នៅកម្ពុជា និង បានចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបប្រមាណ ៥៨% ព្រមទាំងផ្តល់ការងារប្រមាណ ៧៣% នៃចំនួនកម្លាំងពលកម្មសរុបនៅកម្ពុជា ។

ជារួម, ដើម្បីលើកស្ទួយសហគ្រាសធុនតូច និង មធ្យម ជាពិសេស សហគ្រាសក្នុងវិស័យអាទិភាពដូចជម្រាបជូនខាងលើ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន ដូចជា៖ (១)-ការដាក់ជាបន្ទុករបស់រដ្ឋនូវពន្ធនាំចូលឧបករណ៍, គ្រឿងម៉ាស៊ីន និង គ្រឿងចក្រ ជាដើម; (២)-ការបង្កើតឱ្យមានមូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និង សហគ្រិនខ្មែរ; (៣)-ការបង្កើតធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank); (៤)-ការអនុវត្តកម្មវិធីសហហិរញ្ញប្បទាន តាមរយៈធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank) និង កម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ឥណទានក្នុងអត្រាការប្រាក់សម្បទានសម្រាប់វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB); និង (៥)-ការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ក្នុងការផ្តល់ការធានាឥណទានទៅសហគ្រាសដែលជួបនូវកង្វះខាតទ្រព្យបញ្ចាំ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ក្នុងឱកាសនេះ, ខ្ញុំសូមជម្រាបជូនអង្គប្រជុំឱ្យបានជ្រាបផងដែរថា ក្នុងអំឡុងឆ្នាំ ២០២០ កន្លងទៅ, រាជរដ្ឋាភិបាលបានផ្តួចផ្តើម និង អនុវត្តកម្មវិធីសហហិរញ្ញប្បទាន ដំណាក់កាលទី ១ តាមរយៈយន្តការធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank) ដែលជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុឯកជន ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និង មធ្យម ក្នុងទំហំទឹកប្រាក់សរុបចំនួន ១០០ លានដុល្លារអាមេរិក ដែលក្នុងនោះ រាជរដ្ឋាភិបាលចូលរួមបដិភាគចំនួន ៥០ លានដុល្លារអាមេរិក និង គ្រឹះស្ថានហិរញ្ញវត្ថុឯកជនចូលរួមចំនួន ៥០ លានដុល្លារអាមេរិក ។ ដោយមើលឃើញពីការទទួលបានលទ្ធផលជាវិជ្ជមានចេញពីការអនុវត្តគម្រោងដំណាក់កាលទី ១ និង តម្រូវការចាំបាច់ក្នុងការបន្តគាំទ្រហិរញ្ញប្បទានដល់សហគ្រាសធុនតូច និង មធ្យម នៅអំឡុងពេលវិបត្តិ, រាជរដ្ឋាភិបាលបានសម្រេចបន្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និង មធ្យម ដំណាក់កាលទី ២ និង ដាក់ឱ្យអនុវត្តនៅខែសីហា ឆ្នាំ ២០២១ ដែលមានទំហំទឹកប្រាក់សរុបចំនួន ១៤០ លានដុល្លារអាមេរិក ដែលក្នុងនោះ ៧០ លានដុល្លារអាមេរិកត្រូវបានចូលរួមបដិភាគដោយរាជរដ្ឋាភិបាល និង ៧០ លានដុល្លារអាមេរិកទៀតត្រូវបានចូលរួមដោយគ្រឹះស្ថានហិរញ្ញវត្ថុឯកជន ។ គិតត្រឹម ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២, ការអនុវត្តគម្រោងដំណាក់កាលទី ២ នេះ សម្រេចបានប្រមាណ ៩០% ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាល តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) ក៏បានអនុវត្តកម្មវិធីហិរញ្ញប្បទានពិសេស (១)-ក្នុងទំហំមូលនិធិសរុបចំនួន ៧៣ លានដុល្លារអាមេរិក គាំទ្រដល់វិស័យស្រូវ-អង្ករ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ និង ជំរុញការនាំចេញ និង (២)-ក្នុងទំហំមូលនិធិចំនួន ៥០ លានដុល្លារអាមេរិក គាំទ្រសិប្បកម្ម, សហគ្រាសធុនតូច និង មធ្យម ក្នុងវិស័យកសិកម្ម ដែលរួមមាន៖ ការចិញ្ចឹមសត្វ, ការដាំដុះបន្លែ-ផ្លែឈើ, វារីវប្បកម្ម និង ការកែច្នៃផលិតផលកសិកម្ម ។ តាមរយៈកម្មវិធីហិរញ្ញប្បទានពិសេសនេះ, សហគ្រាសក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម មានលទ្ធភាពពង្រឹងអាជីវកម្ម និង ធ្វើឱ្យប្រសើរឡើង នូវខ្សែច្រវាក់ផលិតកម្ម ក្នុងគោលដៅពង្រឹងភាពប្រកួតប្រជែង, រក្សាសន្តិសុខស្បៀងអាហារ និង ជំរុញទាំងការនាំចេញ ក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ ។

ក្នុងន័យនេះ, ដើម្បីបន្តជួយគាំទ្រឥណទានក្នុងអត្រាការប្រាក់សម្បទាន ទៅសហគ្រាសធុនតូច និង មធ្យម និង វិស័យកសិកម្ម, រាជរដ្ឋាភិបាលបានសម្រេចបន្ថែមថវិកាចំនួន ៥០ លានដុល្លារអាមេរិក ដល់ធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank) សម្រាប់បន្តគម្រោង

សហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និង មធ្យម ដំណាក់កាលទី ២ ដែលធ្វើឱ្យបដិភាគរបស់រាជរដ្ឋាភិបាល មានចំនួនដល់ ១២០ លានដុល្លារអាមេរិក ។ ដោយឡែក, ថវិកាបន្ថែមចំនួន ៥០ លានដុល្លារអាមេរិកផ្សេងទៀត បានផ្តល់ជូនទៅធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) សម្រាប់កម្មវិធីហិរញ្ញប្បទានពិសេស ដែលក្នុងនោះ ថវិកា ១០ លានដុល្លារអាមេរិកនឹងប្រើប្រាស់ក្នុងវិស័យស្រូវ-អង្ករ និង ៤០ លានដុល្លារអាមេរិកទៀត នឹងប្រើប្រាស់សម្រាប់ការផ្តល់ហិរញ្ញប្បទានផ្ទាល់ (Direct Lending) ៥០% និង សម្រាប់កម្មវិធីសហហិរញ្ញប្បទានចែករំលែកហានិភ័យជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ (Risk Sharing Syndicated Facilities) ៥០% សំដៅគាំទ្រដល់អនុវិស័យផ្លែឈើ, ការចិញ្ចឹមសត្វ, វារីវប្បកម្ម, និង ការកែច្នៃផលិតផលកសិកម្ម ជាដើម ។

ឆ្លៀតឱកាសនេះដែរ, ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ ចំពោះការចូលរួមរបស់គ្រឹះស្ថានហិរញ្ញវត្ថុឯកជនជាមួយរាជរដ្ឋាភិបាល ក្នុងកិច្ចការដ៏មានសារៈសំខាន់នេះនាពេលកន្លងមក ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ដែលជាតំណាងគ្រឹះស្ថានហិរញ្ញវត្ថុឯកជនទាំងអស់ នឹងបន្តចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការលើកស្ទួយការអភិវឌ្ឍ និង គាំទ្រការរក្សាលំនឹងអាជីវកម្មរបស់សហគ្រាសធុនតូច និង មធ្យម ក្នុងគ្រាដ៏លំបាកនេះ និង ត្រៀមខ្លួនងើបឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈកម្មវិធីហិរញ្ញប្បទាននានា នាពេលខាងមុខ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ខ្ញុំសូមគូសបញ្ជាក់ផងដែរថា អន្តរាគមន៍នាពេលនេះគ្រាន់តែជាចំណែកតូចមួយ ក្នុងការចូលរួមបំពេញតម្រូវការហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់ ដោយសហគ្រាសធុនតូច និង មធ្យម, សហគមន៍កសិកម្ម, និង កសិករតែប៉ុណ្ណោះ ។ ដូច្នេះ, ការចូលរួមរបស់គ្រឹះស្ថានហិរញ្ញវត្ថុឯកជនទាំងអស់ ក្នុងការពិនិត្យលទ្ធភាពផ្តល់ឥណទានទៅសហគ្រាសធុនតូច និង មធ្យម ក្នុងវិស័យអាទិភាពដូចដែលខ្ញុំបានជម្រាបជូនខាងលើ ដោយប្រើប្រាស់ដើមទុនផ្ទាល់របស់គ្រឹះស្ថានខ្លួន ពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយសម្រាលសម្ពាធអាជីវកម្ម ក៏ដូចជាការជួយគាំទ្រសហគ្រាសទាំងនោះ ឱ្យរៀបចំខ្លួនក្នុងការពង្រីកអាជីវកម្ម និង ផលិតកម្ម ដែលនឹងរួមចំណែកក្នុងការបង្កើតការងារ ព្រមទាំងការគាំទ្រក្នុងការសម្រេចបាន នូវកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និង បរិយាប័ន្ន ក្នុងរយៈពេលមធ្យម និង វែង ។

មុននឹងបញ្ចប់, ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័ន និង ភាគីពាក់ព័ន្ធទាំងអស់ ផ្តល់កិច្ចសហប្រតិបត្តិការ ប្រកបដោយស្មារតីបុរេសកម្ម និង ការទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមអនុវត្ត **ក្របខណ្ឌ**

**យុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២១-២០២៣** ឱ្យមានប្រសិទ្ធភាពខ្ពស់ និង សម្រេចឱ្យបាន តាមក្របខណ្ឌពេលវេលាជាក់លាក់ដែលបានកំណត់ ។ ក្នុងករណីដែលក្រសួង-ស្ថាប័ន មានតម្រូវការជំនួយ ក្នុងការអនុវត្តវិធានការណាមួយ ដែលបានដាក់ចេញ ដូចជាការរៀបចំផែនការសកម្មភាព ជាដើម, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្តល់ការគាំទ្រ, សម្របសម្រួល និង អន្តរាគមន៍ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទៅតាមការជាក់ស្តែង ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, សមាជិក និង សមាជិកា**ទាំងអស់នៃអង្គពិធីទាំងមូល មានសុខភាពល្អ, ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និង មានសុភមង្គលក្នុងក្រុមគ្រួសារ ព្រមទាំងជៀសផុតពីជំងឺកូវីដ-១៩ ។

ជំនួសមុខឱ្យប្រមុខរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **"កញ្ចប់ថវិកាចំនួន ១០០ លានដុល្លារអាមេរិក"** តាមរយៈធនាគាររដ្ឋទាំងពីរ សម្រាប់គាំទ្រ និង ជំរុញដល់ការស្តារសេដ្ឋកិច្ចឡើងវិញ ចាប់ពីពេលនេះតទៅ ។

***សូមអរគុណ!***